00642747

E9/3/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់ អៀង សារី ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងញត្តិរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងដឹកនាំការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលត្រូវបានស្នើសុំ និងសំណើសុំផ្អាកបន្ទាន់លើដីកាបង្គាប់ឲ្យដាក់សម្ភារៈតស៊ូមតិ សម្រាប់ត្រៀមរៀបចំសវនាការ**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូ ឧត្តរា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារដើម**

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 02 / 2011

ម៉ោង (Time/Heure): 15:40

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់មេធាវីការពារក្តី (“ញត្តិ”)[1] សុំឱ្យមានការកែប្រែការដឹកនាំនីតិវិធីសវនាការជំនុំជម្រះនៅ អវតក និងសុំផ្អាកដីការបស់អង្គជំនុំជម្រះសាលាដំបូង[2]បង្គាប់ឱ្យដាក់សម្ភារៈភស្តុតាង សម្រាប់ការត្រៀមសវនាការជំនុំជម្រះ (“ចម្លើយតប”)[3] ។

## I ការឆ្លើយតប

១. នៅក្នុងកថាខណ្ឌទី២(ក) នៃចម្លើយតបរបស់ កសព ថ្លែងថា “អង្គជំនុំជម្រះសាលាដំបូងមិនមែនជាវេទិកាត្រឹមត្រូវសម្រាប់ស្វែងឱ្យមានការកែប្រែវិធានផ្ទៃក្នុងទេ ហេតុដូចនេះ ញត្តិស្នើសុំមិនអាចទទួលយកបានឡើយ”[4] ។ ការធ្វើវិសោធនកម្មនីតិវិធីដែលបានស្នើសុំ គឺស្ថិតនៅក្នុងវិធានផ្ទៃក្នុង[5]។ កសព បានស្នើថា មេធាវីការពារក្តីគួរតែបានស្នើសុំឱ្យធ្វើវិសោធនកម្មលើវិធានណាមួយនៅកិច្ចប្រជុំពេញអង្គ តាមរយៈអង្គភាពគាំពារការការពារក្តី (“DSS”)។ ជបឋម មិនដូចគ្នានឹង កសព មេធាវីការពារក្តី មិនអាចចូលរួមកិច្ចប្រជុំពេញអង្គរបស់ចៅក្រមដោយផ្ទាល់បានទេ ។ មេធាវីការពារក្តីអាចចូលរួមកិច្ចប្រជុំពេញអង្គរបស់ចៅក្រមតាមរយៈអង្គភាព DSS តែប៉ុណ្ណោះ ។ អង្គភាព DSS ត្រូវតែធ្វើឱ្យមានតុល្យភាពនៃផលប្រយោជន៍ដែលប្រកួតប្រជែងសម្រាប់គ្រប់

[1] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង, ញត្តិរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដំណើរការសវនាការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលត្រូវបានស្នើសុំ និងសំណើផ្អាកជាបន្ទាន់ដីកាបង្គាប់ដាក់សម្ភារៈភស្តុតាងដើម្បីរៀបចំសវនាការជំនុំជម្រះ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ E9/3, ERN: 00640920-00640935។

[2] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង, ដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដាក់សម្ភារៈភស្តុតាង សម្រាប់ត្រៀមរៀបចំសវនាការជំនុំជម្រះ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ E9, ERN: 00635754-00635759 (“ដីកា”)។

[3] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដំណើរការសវនាការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសធនកម្មនីតិវិធីដែលត្រូវបានស្នើសុំ និងសំណើសុំពន្លឿនការបន្តដាក់សម្ភារៈភស្តុតាង ដើម្បីរៀបចំសវនាការជំនុំជម្រះ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ E9/3, ERN: 00641756-00641760។

[4] ដូចខាងលើ នៅកថាខណ្ឌទី២(ក) ។

[5] ញត្តិ នៅកថាខណ្ឌទី៣២ ។

ក្រុមការពារក្តីទាំងអស់ ។ កសព មិនមានផលប្រយោជន៍ប្រកួតប្រជែងនេះទេ ។ ទីពីរ កសព ហាក់ដូចជាបញ្ចូលក្រុមការពារក្តីទាំងអស់ជាស្ថាប័នតែមួយ ។ វាហាក់ដូចជាថាជនជាប់ចោទទាំងបួននាក់ត្រូវបាន កសព វិនិច្ឆ័យទុកជាមុនថាជាក្រុមដែលមានលក្ខណៈរួមតែមួយ (monolithic enterprise) ខណៈដែល អង្គជំនុំជម្រះសាលាដំបូង ទំនងជាសន្មតផងដែរថា ជនជាប់ចោទទាំងបួនគួរធ្វើការជាក្រុមនៅក្នុងដាក់សារណានានា[6]។ ចំណុចនេះគឺផ្ទុយគ្នាទៅនឹងទស្សនៈដែលបានបង្កើតយ៉ាងត្រឹមត្រូវថា ជនជាប់ចោទទាំងឡាយ ត្រូវទទួលបានសិទ្ធិទទួលបានការប្រព្រឹត្តមកលើក្នុងលក្ខណៈជាបុគ្គលម្នាក់ដាច់ដោយឡែក។ ខណៈដែលវាអាចមានលក្ខណៈងាយស្រួលសម្រាប់ កសព និង អង្គជំនុំជម្រះសាលាដំបូង បើសិនជាជនជាប់ចោទទាំងបួននាក់ ដាក់សារណារួមគ្នា បញ្ហាដែលនៅតែមាននោះគឺថា ជនជាប់ចោទម្នាក់ៗ មានក្រុមមេធាវីការពារក្តីរៀងៗខ្លួន មានការណែនាំរៀងៗខ្លួន និងប្រកាន់យកនូវវិធីសាស្ត្ររៀងៗខ្លួន។ ការប្រព្រឹត្តមកលើជនជាប់ចោទម្នាក់ក្នុងនាមជាបុគ្គលឯកជនដាច់តែឯង គឺមានចែងដោយរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងថា ពលរដ្ឋកខ្មែរទាំងឡាយត្រូវតែបានគេប្រព្រឹត្តមកលើក្នុងនាមជាបុគ្គលឯកជន នៅចំពោះមុខច្បាប់ មិនមែនជាសមូហភាពឡើយ[7]។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (“UDHR”) ដែលត្រូវតែបានគេគោរពនៅកម្ពុជា ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា[8] ក៏ចែងផងដែរថា បុគ្គលម្នាក់ត្រូវតែបានគេប្រព្រឹត្តមកលើក្នុងលក្ខណៈជាបុគ្គលឯកជននៅចំពោះមុខច្បាប់ មិនមែនជាលក្ខណៈ

---

[6] “អង្គជំនុំជម្រះសាលាដំបូងលើកទឹកចិត្តឲ្យក្រុមមេធាវីការពារក្តី សម្របសម្រួលសំណើរបស់ពួកគេនៅពេលណាដែលអាចធ្វើបាន និងនៅករណីយុទ្ធសាស្ត្រជាយុទ្ធសាស្ត្ររួម ដើម្បីដាក់ញត្តិរួមនៅអង្គជំនុំជម្រះ” ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ, អនុស្សរណៈក្នុងការិយាល័យបញ្ជូនពី Susan Lamb មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង ទៅភាគីទាំងអស់នៅក្នុងករណី ០០២, ការជូនដំណឹងជាមុននៃការសម្រេចរបស់អង្គជំនុំជម្រះលើញត្តិ ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០១១ E14, E15, E9/2, E9/3, E/24 and E27,។

[7] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៩៩ ចែងក្នុងផ្នែកពាក់ព័ន្ធថា "ប្រជា<u>ពលរដ្ឋខ្មែរ</u>មានភាពស្មើគ្នាចំពោះមុខច្បាប់"។ (គូសបញ្ជាក់បន្ថែម)

[8] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៩៩ ចែងក្នុងផ្នែកពាក់ព័ន្ធថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

សមូហភាពឡើយ[9]។ សេចក្ដីណែនាំបន្ថែមពីនេះគេអាចស្វែងរកបានពីតុលាការ ICTY ដែលបានសម្រេចថា "ក្នុងការកំណត់តួនាទីរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវរក្សាទុកនូវការពិចារណារបស់ខ្លួននូវ ... គោលការណ៍ដែលការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនីមួយៗត្រូវតែពិចារណាដាច់ដោយឡែកពីគ្នា។ បញ្ហាដែលជនជាប់ចោទត្រូវបានជំនុំជម្រះរួមគ្នានោះ មិនមែនមានន័យថា ការចោទប្រកាន់លើពួកគាត់ មិនអាចត្រូវបានទទួលការពិចារណាដាច់ដោយឡែកនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បានផ្ដល់ការពិចារណាដាច់ដោយឡែកពីគ្នាទៅលើសំណុំរឿងក្ដីរបស់ជនជាប់ចោទនីមួយៗ"[10]។

២. នៅក្នុងកថាខណ្ឌ២(គ) នៃចម្លើយតបរបស់ កសព ថ្លែងថាញត្តិស្នើសុំនេះមានកំហុស ដោយសារមេធាវីការពារក្ដីយល់ខុសពីប្រព័ន្ធច្បាប់ស៊ីវិលឡូ ។ អវតក បានប្រែក្លាយទៅជាអនុវត្តប្រព័ន្ធនីតិវិធីចំរុះ ដោយផ្ទុកផ្ដាក់បន្ទុកនៃការបង្ហាញភស្ដុតាងមកលើ កសព ។ ចំនុចនេះកាន់តែច្បាស់តាមរយៈការកែប្រែនូវវិធាននផ្ទៃក្នុង[11]។

៣. នៅកថាខណ្ឌ ២(គ)(i) ចែងថា ជាផលវិបាកដែលលេចចេញពីគោលការណ៍សច្ចធារណ៍នៃនិរទោស អយ្យការនៅក្នុងប្រទេសដែលប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិលឡូមានបន្ទុកបង្ហាញពិរុទ្ធភាព ។ កសព កំពុងភ័ន្តច្រលំប្រព័ន្ធច្បាប់នីតិវិធីស៊ីវិលឡូ នឹងនីតិវិធីចំរុះនៅ អវតក ។ អវតក គឺជាតុលាការ តុលាការដែលមានដើមកំណើតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ អវតក បានអនុម័តយកសារធាតុមួយចំនួនពីប្រព័ន្ធនីតិវិធីចំពោះមុខ ដូចជា កសព មានបន្ទុកបង្ហាញពិរុទ្ធភាពសិទ្ធិដែលផ្ដល់ទៅ កសព និងមេធាវីការពារក្ដី ក្នុងការធ្វើសេចក្ដីថ្លែងដំបូង[12] និងបង្ហាញភស្ដុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជាអាទិ៍[13]។

---

[9] មាត្រា ៦ UDHR ចែងថា "មនុស្សគ្រប់រូបមានសិទ្ធិអោយគេទទួលស្គាល់នៅគ្រប់ទីកន្លែង ថាជាបុគ្គលម្នាក់នៅចំពោះមុខច្បាប់"។

[10] ករណីរដ្ឋអាជ្ញា ទល់នឹង *Kupreškić និងអ្នកដទៃទៀត l.*, IT-95-16-T, សាលក្រម ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០០ នៅកថាខណ្ឌទី ៣៣៩ (ខ)។

[11] ញត្តិ កថាខណ្ឌទី១១-១២ ។

[12] វិធាន ៨៩ស្ទួន(២) ចែងថា "នៅមុនពេលសួរចម្លើយជនជាប់ចោទ សហព្រះរាជអាជ្ញា អាចធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ។ ជនជាប់ចោទ ឬ មេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន"។

[13] វិធាន ៨០ ។ *សូមមើលផងដែរ* ញត្តិ កថាខណ្ឌ ១១-១២។

៤. នៅក្នុងកថាខណ្ឌទី២(គ)(ii) នៃចម្លើយតបរបស់ កសព ថែងថាពុំមានភាពតានតឹងរវាងតួនាទីរបស់សហព្រះរាជអាជ្ញាចំពោះបន្ទុកបង្ហាញភស្តុតាង និងតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិត ។ មេធាវីការពារក្តីទទួលស្គាល់ចំណុចនេះនៅក្នុងញត្តិរបស់ខ្លួន[14]។ មេធាវីការពារក្តីគ្រាន់តែកត់សម្គាល់ថាតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូង និងតួនាទីរបស់សហព្រះរាជអាជ្ញា "ត្រូវតែបានពិចារណាសមស្របតាមការផ្លាស់ប្តូរបន្ទុកនៃការបង្ហាញភស្តុតាងមកលើសហព្រះរាជអាជ្ញា ដែលផ្ទុយនឹងតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិត និងគំរូនានានៃនីតិវិធីជំនុំជម្រះដែលមានលក្ខណៈនៃការបើកឱ្យភាគីតទល់គ្នាដែលវិធានផ្ទៃក្នុងបានគ្រោងយ៉ាងច្បាស់"[15] ។

៥. នៅក្នុងកថាខណ្ឌទី២(គ)(ii) នៃចម្លើយតបរបស់ កសព ថែងថាមេធាវីការពារក្តីភាន់ច្រឡំ " នីតិវិធីតាមប្រព័ន្ធ (adversarial) ដែលបើកឱ្យភាគីទល់គ្នា ជាមួយនឹង "នីតិវិធីចោទប្រកាន់" (accusatorial system) ហើយថាប្រព័ន្ធដែលបើកឱ្យមានការសួរដេញដោល (inquisitorial system) នឹងគោរពនីតិវិធីដែលមានចរិតលក្ខណៈបើកឱ្យភាគីតទល់គ្នា ដូចដែលបានបញ្ជាក់ដោយវិធាន ២១(១)(ក)។ មេធាវីការពារក្តីមិនបានភាន់ច្រឡំនោះទេ ទោះជាតាមវិធីណាក៏ដោយ។ ដំណើរការនីតិវិធីនៅ អវតក គឺជានីតិវិធីចំរុះរវាងនីតិវិធីតាមបែបសួរដេញដោល និងនីតិវិធីដែលមានលក្ខណៈបើកឱ្យភាគីតទល់គ្នា ដូចដែលបានបង្ហាញដោយការសម្រេចរបស់ អវតក បានដកចេញក្រមនីតិវិធីព្រហ្មទណ្ឌ និងបានដាក់បញ្ចូលចរិតលក្ខណៈ adversarial កាន់តែច្រើននៅ អវតក[16]។ ការភ័ន្តច្រលំទំនងជាមកពីខាង កសព ដែលពីមុន កសព បានពិព័ណ៌នាថា ប្រព័ន្ធចោទប្រកាន់ គឺដូចជាប្រព័ន្ធតទល់ចំពោះមុខដែរ ពោលគឺ "វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុងរៀបរាប់អំពីដំណើរការនីតិវិធីនៅចំពោះមុខ អវតក ថាជាប្រព័ន្ធចំពោះមុខដែលជាការពិព័ណ៌នាបែបបុរាណនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌរបស់ប្រព័ន្ធខំម៉ុនឡូ" [17]។

---

[14] ដូចខាងលើ នៅកថាខណ្ឌទី១៤ ។

[15] ដូចខាងលើ ។

[16] ញត្តិ កថាខណ្ឌទី១២ ។

[17] អនុស្សារណៈអន្តរការិយាល័យរបស់ ការិយាល័យសហព្រះរាជអាជ្ញា ទៅកាន់ Susan Lamb មន្ត្រីសម្របសម្រួលកិច្ចការតុលាការ ក្រោមចំណងជើងថា "សំណើសុំវិសោធនកម្មវិធានចំនួនពីរ នៃវិធានផ្ទៃក្នុង ដើម្បីធានាអោយនីតិវិធីជំនុំជម្រះមាន

៦. នៅក្នុងកថាខណ្ឌទី២(ង) និង២(ច) នៃចម្លើយតបរបស់ កសព ចែងថាសហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងសំណើសុំផ្អាកលើដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ ("ដីកា")[18]។ ដោយមើលឃើញថាអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ ភាគីរួចហើយថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនផ្អាកដីកាឡើយ[19] ហេតុដូច្នេះចំណុចនេះអាចយកមកពិភាក្សា ។

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលទាំងអស់ដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្ដីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ដឹកនាំសវនាការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើ

ខ. កោះប្រជុំដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងញត្តិនេះ ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

ប្រសិទ្ធិភាព ទាក់ទងនឹង (១) ការពិនិត្យភស្តុតាងនៅក្នុងការជំនុំជម្រះក្ដី និង (២) ការចោទសួរជនជាប់ចោទ និងសាក្សី" ចុះថ្ងៃទី ២០ មេសា ២០១០ ទំព័រ ៥-៦។

[18] ដីកា ។

[19] អនុស្សារណៈអន្តរការិយាល័យ ។